00518857

Declassified to Public
06 September 2012

E181/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 05 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 20 / 05 / 2010
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## អនុស្សរណៈ

**ពី៖** លោក **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ទៅ៖** លោក Richard ROGERS ប្រធានផ្នែកគាំពារការការពារក្តី

**កាលបរិច្ឆេទ៖** ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០

**កម្មវត្ថុ៖** សំណើសុំការអនុញ្ញាតចូលជួបលោក **កាំង ហ្គេកអ៊ាវ**

**ឈ្មោះសំណុំឯកសារ៖** K-14-DSS-Ltr CIJ Visit Permission-CE-11.03.10

១ ដោយយោងតាមអនុស្សរណៈរបស់លោក កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ លោកបានបញ្ជាក់ថាលោក Francois ROUX បច្ចុប្បន្នជាសហមេធាវីអន្តរជាតិរបស់លោក កាំង ហ្គេកអ៊ាវ នឹងមិនអាចតំណាងលោក កាំង ហ្គេកអ៊ាវ ក្នុងបណ្តឹងសារទុក្ខ ដែលអាចនឹងកើតមាន ក្រោយពេលអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមបាននោះទេ។ អាស្រ័យហេតុនេះគាត់ចាំបាច់ ត្រូវជ្រើសរើសសហមេធាវីមួយរូប ដើម្បីមកជំនួស និងដើម្បីតំណាងគាត់ក្នុងករណីអាចមានបណ្តឹងសារទុក្ខ។

២ អនុលោមតាមវិធាន១១នៃវិធានផ្ទៃក្នុង និងតាមបញ្ញត្តិរដ្ឋបាលរបស់ផ្នែកគាំពារការការពារក្តី និងដើម្បីធានាឱ្យសហមេធាវីថ្មីបានត្រៀមខ្លួនរួចជាស្រេច មុននឹងចូលការពារក្តីក្នុងករណីមានបណ្តឹងសារទុក្ខ ផ្នែកគាំពារការការពារក្តីមានបំណងចង់ចាប់ផ្តើមដំណើរការជ្រើសរើសសហមេធាវីថ្មី ដោយការជួបពិគ្រោះជាមួយលោក កាំង ហ្គេកអ៊ាវ។ ដោយសារហេតុផលនេះ ទើបផ្នែកគាំពារការការពារក្តីបានស្នើមកអង្គជំនុំជម្រះសាលាដំបូង សុំការអនុញ្ញាតចូលជួបលោក កាំង ហ្គេកអ៊ាវ ក្នុងមន្ទីរឃុំឃាំង។

៣ សំណើរបស់លោក ដែលសុំការអនុញ្ញាតចូលជួបលោក កាំង ហ្គេកអ៊ាវ ដើម្បីពិគ្រោះបញ្ហានេះត្រូវបានឯកភាពហើយ។ យើងបានកត់សម្គាល់ឃើញថា សមាសភាពអ្នកដែលត្រូវអមដំណើរចូលទៅជួបនោះមាន លោក Richard ROGERS ជាប្រធានផ្នែកគាំពារការការពារក្តី លោក Christopher ENGELS ជាអនុប្រធានផ្នែកគាំពារការការពារក្តី និងអ្នកបកប្រែផ្ទាល់ មាត់មួយនាក់។